# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-May-2012, 09:24
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យពិនិត្យមើលឡើងវិញ នូវប្រតិចារឹកសវនាការជាភាសាបារាំង

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

Original FR: 00808114-00808125

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា អ៊ុច ស្រីផាត

លោក Samy SALAMON

កញ្ញា Soumeya MEDJEBEUR

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## បញ្ហាពាក់ព័ន្ធនឹងការបកប្រែបណ្តញផ្ទាល់មាត់ពីភាសាខ្មែរទៅអង់គ្លេសបន្ទាប់មកទៅបារាំង

១. ចាប់តាំងពីពេលចាប់ផ្តើមសវនាការលើអង្គសេចក្តីមក មេធាវីការពារក្តីលោក ខៀវ សំផន ជួបប្រទះនូវការលំបាកនានាពាក់ព័ន្ធនឹងការបកប្រែបណ្តញផ្ទាល់មាត់នៃកិច្ចពិភាក្សាដេញដោល ក្នុងសវនាការ។ បញ្ហានេះចោទឡើងជាពិសេស នៅពេលសាក្សីផ្តល់សក្ខីកម្មជាភាសាខ្មែរ។ ជាការពិតភាសាខ្មែរត្រូវបានបកប្រែជាពីរដំណាក់កាលបន្តបន្ទាប់គ្នា ជាដំបូងទៅអង់គ្លេស បន្ទាប់មកពីអង់គ្លេសទៅបារាំង។ ស្ថានភាពនេះបណ្តាលឲ្យមានកំហុស និងបាត់ខ្លឹមសារ។

២. មេធាវីការពារក្តីលោក ខៀវ សំផន បានធ្វើសំណើដោយផ្ទាល់មាត់ជាច្រើនលើកច្រើនសា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យសាក្សីនិយាយយឺតៗ និងបង្គាប់ឲ្យភាគីទុកពេល រវាងសំណួរ និងចម្លើយ។ សំណើទាំងនេះមានគោលដៅជៀសវាងការបាត់ខ្លឹមសារនៃសក្ខីកម្ម នៅក្នុងការបកប្រែផ្ទាល់មាត់ជាភាសាបារាំង[1]។ លោកប្រធានតែងតែរំឭកពីបញ្ហានេះជាប្រចាំ[2] ដែលនេះបង្ហាញថាបញ្ហាកើតឡើងដដែលៗ។

៣. ជាក់ស្តែង នៅពេលសួរឆ្លើយរវាងបុគ្គលពីររូបជាភាសាខ្មែរ ឬជាភាសាខ្មែរ-អង់គ្លេស ជាញឹកញាប់អ្នកបកប្រែជាភាសាបារាំងមិនមានលទ្ធភាពបញ្ចប់ការបកប្រែមួយឃ្លាមុនពេលឆ្លើយ។ ការលំបាកទាំងនេះបន្ថែមទៅលើបញ្ហាបច្ចេកទេសពាក់ព័ន្ធនឹងការបកប្រែកិច្ចពិភាក្សាដេញដោល[3]។

---

[1] សវនាការ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/50.1 ទំព័រ ៣៦-៣៧ ; សវនាការ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/52.1 ទំព័រ ៥-៦ និងទំព័រ ៧-៨ ; សវនាការ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/64.1 ទំព័រ ៣៩-៤០ និងទំព័រ ៤៧។

[2] ឧទាហរណ៍ត្រួសៗ៖ សវនាការ ថ្ងៃទី 0៦ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ E1/17.1 ទំព័រ ៣៥-៣៦ ; សវនាការ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/26.1 ទំព័រ ២៣ ; សវនាការ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/33.1 ទំព័រ ៥៦-៥៧ និងទំព័រ ៦៤-៦៥ ; សវនាការ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/34.1 ទំព័រ ១៤-១៥ ; សវនាការ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/36.1 ទំព័រ ៩-១០ ; សវនាការ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/53.1 ទំព័រ ១ ; សវនាការ ថ្ងៃទី 0៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/61.1 ទំព័រ ៣១-៣២ ; សវនាការ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/66.1 ទំព័រ ៥៤-៥៥។

[3] សវនាការ ថ្ងៃទី 0៧ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E1/18.1៖ ការបកប្រែសវនាការមានការលំបាក ដោយសារតែមានបញ្ហា

៤. ការលំបាកទាំងនេះបណ្ដាលឲ្យមានភាពច្របូកច្របល់ ក្នុងការបកប្រែជាភាសាបារាំង ដែលធ្វើឲ្យប៉ះពាល់ដល់ខ្លឹមសារសំខាន់នៃសក្ខីកម្មរបស់សាក្សី។ លោកប្រធានបានរំឭកថា អ្នកបកប្រែចាំបាច់ត្រូវមានភាពប្រុងប្រយ័ត្នខ្ពស់ នៅពេលបកប្រែកាលបរិច្ឆេទ ពីព្រោះក្នុងករណីមានការភាន់ច្រឡំ សក្ខីកម្មក្លាយជាមានលក្ខណៈ *"កំបុត"*[4]។ ក៏ប៉ុន្តែ ការតម្រូវបែបនេះមិនអាចអនុវត្តបានទេ នៅពេលអ្នកបកប្រែបារាំងទទួលបានការបកប្រែជាភាសាអង់គ្លេសពីភាសាខ្មែរ ក្នុងពេលដំណាលគ្នាដែលកិច្ចពិភាក្សាដេញដោលកំពុងបន្តទៅមុខទៀតនោះ។

៥. ភាពច្របូកច្របល់បែបនេះ ដែលត្រូវបានលើកឡើង និងពិភាក្សាជារឿយៗដោយភាគីក្នុងសវនាការ ធ្វើឲ្យនីតិវិធីមានភាពយឺតយ៉ាវ[5]។ ឧទាហរណ៍ សវនាការ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ បង្កឲ្យមានការជំទាស់ពីសំណាក់មេធាវីការពារក្ដីលោក អៀង សារី និងលោក ខៀវ សំផន បន្ទាប់ពីមាន ភាពមិនស៊ីគ្នារវាងការបកប្រែជាភាសាបារាំង ខ្មែរ និងអង់គ្លេស ពាក់ព័ន្ធនឹងគោលដៅនៃទស្សនកិច្ចរបស់លោក សាឡុត បាន (សាក្សី TCW-586) នៅមន្ទីរបឹងត្របែក[6]។

៦. ភាពមិនត្រឹមត្រូវនៃការបកប្រែជាភាសាបារាំង អាចជាឧបសគ្គមួយដល់ការរៀបចំការជំទាស់របស់ភាគី ក៏ដូចជាបង្កព្យសនកម្មដល់ការត្រៀមលក្ខណៈសួរសំណួរ ក្នុងករណីគ្មានប្រតិចារឹក។

**<u>បញ្ហាពាក់ព័ន្ធនឹងភាពមិនត្រឹមត្រូវនៃប្រតិចារឹកសវនាការជាភាសាបារាំង</u>**

---

បច្ចេកទេសពាក់ព័ន្ធនឹងសក្ខីកម្មតាមវីដេអូ ; សវនាការ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/69.1 ទំព័រ ២៖ អន្តរាគមន៍របស់មេធាវី Karnavas ស្ដាប់មិនឮនៅដើមដំបូង ដោយសារតែប្រើប៊ុស្ដិ៍ជាប់រវល់ ; សវនាការ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ E1/71.1 ទំព័រ ១០-១១៖ មានបញ្ហាប៊ុស្ដិ៍ធ្វើឲ្យមិនអាចបកប្រែជាភាសាបារាំងបាននូវសំណួរ-ចម្លើយជាច្រើនរវាងមេធាវី គង់ សំអុន និងលោក សាឡុត បាន (សាក្សី TCW-586)។

[4] ឧទាហរណ៍ពីកំហុសកាលបរិច្ឆេទ៖ សវនាការ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១១ ឯកសារ E1/25.1 ទំព័រ ៣៣-៣៤ ; សវនាការ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/26.1 ទំព័រ ២៣ ; សវនាការ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/55.1 ទំព័រ ៧២ និង ៧៣ ; សវនាការ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/60.1 ទំព័រ ១៣-១៥៖ បកប្រែខុសកាលបរិច្ឆេទ ផ្ទេរ សុន សេន ពេលលោក កាំង ហ្កេចអ៊ាវ ហៅ ឌុច (សាក្សី TCW-281) ផ្ដល់សក្ខីកម្ម ដែលមេធាវី Pestman លើកឡើង។

[5] សវនាការ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/68.1 ទំព័រ ៦៥៖ ចៅក្រម Lavergne បានធ្វើអន្តរាគមន៍ ដើម្បីសុំបំភ្លឺលើបញ្ហាបកប្រែឈ្មោះ ខៀវ ធីរិទ្ធ ឬ ខៀវ ធីរ៉ាត់។

[6] សវនាការ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/68.1 ទំព័រ ៧៦-៧៨។

៧. អ្វីដែលនិយាយនៅក្នុងសវនាការត្រូវតែបកប្រែ។ វិធាន ៩៧ កថាខណ្ឌ ៣ នៃវិធានផ្ទៃក្នុង ចែងថា៖ *"កំណត់ហេតុជាលាយលក្ខណ៍អក្សរប្រចាំថ្ងៃនៃដំណើរការនីតិវិធី ដែលធ្វើឡើងដោយក្រឡាបញ្ជី ត្រូវចាត់ទុកថាមានភាពត្រឹមត្រូវ ផ្ទុះបញ្ចាំងអំពីការប្រព្រឹត្តទៅពិតប្រាកដនៃសវនាការ"* ។ ក៏ប៉ុន្តែ ការបាត់ខ្លឹមសារសំខាន់នៃសក្ខីកម្មនៅក្នុងការបកប្រែ ជះឥទ្ធិពលទៅលើប្រតិចារឹកសវនាការជាភាសាបារាំង។

៨. ការអានឡើងវិញនូវប្រតិចារឹកសវនាការជាភាសាបារាំង បង្ហាញឲ្យឃើញកំហុស និងការបាត់មួយចំនួន ដែលអាចបំប្លែងខ្លឹមសារដើមនៃសក្ខីកម្ម។

៩. ក្នុងករណីមួយចំនួនជាលក្ខណៈគ្រួសៗ មេធាវីការពារក្ដីលោក ខៀវ សំផន បានធ្វើការប្រៀបធៀបសំណៅជាភាសាខ្មែរ និងបារាំង។ នៅក្នុងការបកប្រែទាំងនេះ ផ្នែកគូសបន្ទាត់ពីក្រោមមិនត្រូវបានបកជាភាសាបារាំងនោះទេ ហើយផ្នែកដិតខ្មៅត្រូវបានបកប្រែខុស។

១០. ប្រតិចារឹកនៃសក្ខីកម្មរបស់លោក កាំង ហ្កេចអ៊ាវ ហៅ ឌុច (សាក្សី TCW-281) ផ្ទុះបញ្ចាំងនូវការលំបាកទាំងនេះ ដែលជាប្រភពគួរឲ្យព្រួយបារម្ភយ៉ាងខ្លាំងដល់មេធាវីការពារក្ដីលោក ខៀវ សំផន។

១១. នៅក្នុងសវនាការ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ មានការបាត់មិនតិចជាងប្រាំឃ្លានៅក្នុងសំណៅស្ដាពរនៃប្រតិចារឹកជាភាសាបារាំង[7]។ ឃ្លាទាំងនេះជាខ្លឹមសារសំខាន់នៃសក្ខីកម្មរបស់សាក្សី (ប្រតិចារឹកជាភាសាបារាំង) ៖

> "នៅឆ្នាំ១៩៦៦ លោកសហព្រះរាជអាជ្ញាប្រហែលជាដឹងហើយ មានព្រឹត្តិការណ៍សំខាន់ៗកើតឡើង។ ដូច្នេះ សភាពការណ៍ទាំងនេះនាំឲ្យយើងយល់ឃើញថា រដ្ឋប្រហារអាចកើតឡើងគ្រប់ពេលទាំងអស់"។

ប្រតិចារឹកជាភាសាខ្មែរ៖

> "នៅឆ្នាំ១៩៦៦ លោកសហព្រះរាជអាជ្ញាប្រហែលជាចាំហើយ <u>រដ្ឋសភា នីតិកាល ១៩៦៦-</u>

[7] សវនាការ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/50.1 ទំព័រ ៤០។

១៩៧០ របស់ លន់ នល់ ត្រូវបានបង្កើតឡើង។ កម្លាំងរបស់ព្រឹទ្ធសភា និងរដ្ឋសភាជំនាន់នោះ ជាកម្លាំងរបស់ លន់ នល់ សុទ្ធសាធ។ ខ្ញុំសុំនិយាយ សុទ្ធសាធនេះទៅចុះ លើកលែងតែជនចម្រើនបីនាក់ គឺលោក ខៀវ សំផន លោក ហ៊ូ យន់ និងលោក ហ៊ូ នឹម។ ក្រៅពីនោះ មានកម្លាំងកណ្តាលពីរ ដូចជា កៅ សាន ជាដើម។ នៅសល់ប៉ុន្មានសុទ្ធតែកម្លាំងរបស់ពួក លន់ នល់។ ដូច្នេះ សភាពការណ៍ទាំងនេះនាំឲ្យយើងយល់ឃើញថា រដ្ឋប្រហារអាចកើតឡើងគ្រប់ពេលទាំងអស់"។

១២. នៅក្នុងប្រតិចារឹកជាភាសាបារាំងនៃសវនាការ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ នៅបន្ទាត់ទី ១០[8] មិនមានការបកប្រែចម្លើយរបស់លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច (សាក្សី TCW-281) ដែលបានបញ្ជាក់ថា ការសង្កេតនេះគឺជាការវិភាគផ្ទាល់ខ្លួន និងជាការយល់ឃើញរបស់គាត់ប៉ុណ្ណោះ។

១៣. មានកំហុសជាច្រើននៅក្នុងប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២[9] នៅទំព័រ ៤៩៖

ប្រតិចារឹកជាភាសាបារាំង៖

> "នៅឆ្នាំ១៩៦៧ ខៀវ សំផន និង ហ៊ូ នឹម បាត់ខ្លួន។ អ្នកទាំងនេះជាពួកអនុធនចម្រើន។ ខៀវ សំផន ទទួលបញ្ជាពី ប៉ុល ពត។ គាត់ទទួលភារកិច្ចជាប្រធានមន្ទីរមជ្ឈិម"។

ប្រតិចារឹកជាភាសាខ្មែរ៖

> "នៅឆ្នាំ១៩៦៧ ខៀវ សំផន និង ហ៊ូ នឹម បាត់ខ្លួន។ អ្នកទាំងនេះជាពួកអនុធនចម្រើន។ ខៀវ សំផន ទទួលបញ្ជាពី ប៉ុល ពត។ ពេលចូលទៅនៅជាមួយ ប៉ុល ពត ខ្ញុំបានទទួលដំណឹងជាពិសេសពីបញ្ញាជនថា ខៀវ សំផន ទទួលភារកិច្ចជាប្រធានមន្ទីរមជ្ឈិម"។

១៤. នៅទំព័រ ៩២៖

ប្រតិចារឹកជាភាសាបារាំង៖

> "វន វ៉េត ជាមនុស្សប្រកាន់អាកប្បកិរិយាកណ្តាល។ នៅពេលសម្រេចចាប់ខ្លួន សួស នៅ ហៅ ឈូក បងខៀវ ប្រាប់ឲ្យខ្ញុំរៀបចំឯកសារជាច្រើនដុំ"។ តាមពិត មិនមែនគាត់បញ្ជាទេ

[8] សវនាការ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/51.1 ទំព័រ ៧៧ បន្ទាត់ទី ១០។

[9] សវនាការ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E1/55.1 ទំព័រ ៤៩។

គឺខ្ញុំរៀបចំច្រើនដុំជូនគាត់។ ខ្ញុំបានសួរ ប៉ង់ ថា តើបង វន មានបាននិយាយអ្វីរារាំងការចាប់ខ្លួននេះទេ។ នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ប៉ង់ ប្រាប់ខ្ញុំថា លំបាកធ្វើការជាមួយ វន វ៉េត ណាស់ ពីព្រោះគាត់មិននិយាយអ្វីសោះនៅក្នុងកិច្ចប្រជុំ”។

ប្រតិចារឹកជាភាសាខ្មែរ ផ្សេងពីនេះ៖

“វន វ៉េត ជាមនុស្សប្រកាន់អាកប្បកិរិយាកណ្តាល។ ដូចសហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញក្នុងសេចក្តីរាយការណ៍ខ្ញុំលើកមុនហើយ នៅពេលសម្រេចចាប់ខ្លួន សួស នៅ ហៅ ឈូក បងខៀវ ប្រាប់ឲ្យខ្ញុំរៀបចំឯកសារប្រាំពីរដុំ”។ **ខ្ញុំរៀបចំប្រាំពីរដុំជូនគាត់។ តាមពិតមិនមែនគាត់បញ្ជាមកប្រាំពីរដុំទេ គឺខ្ញុំរៀបចំប្រាំពីរដុំជូនគាត់។** ដូច្នេះ ខ្ញុំជឿថា នៅពេលសម្រេចចាប់ខ្លួន ជូ ជេត ជាសមាជិកមជ្ឈិមពេញសិទ្ធិ ត្រូវមានកិច្ចប្រជុំអចិន្ត្រៃយ៍។ ខ្ញុំបានសួរ ប៉ង់ ថា តើបងវន មានបាននិយាយអ្វីរារាំងការចាប់ខ្លួននេះទេ។ **ប៉ង់ ឆ្លើយថាអត់ទេ។ បងវន នេះលំបាកណាស់ ពេលប្រជុំម្តងៗ ជួនអង្គុយ ជួនធ្វើមុខក្រម៉ូវៗ និយាយអីក៏មិននិយាយ**”។

១៥. នៅទំព័រ ៩៤ នៃប្រតិចារឹកដដែល៖

“ប្រហែលជាម៉ោង ៩ ឬ ១០ ព្រឹក ថ្ងៃទី 0៦ ខែ មករា ឆ្នាំ ១៩៧៤ មានកិច្ចប្រជុំមួយនៅពុទ្ធិកវិទ្យាល័យសុរាម្រិត។ ដោយសារឃើញកិច្ចប្រជុំនេះនិយាយពីឃ្លាំងរដ្ឋ ទើបខ្ញុំគិតថាបងហែម គ្រប់គ្រងអង្គភាពមួយទៀត។ គាត់មិនធ្វើការនៅកន្លែងតែមួយទេ។ ក្រោយមកទៀត ពេលយួនចូលមកដល់ ពួកយើងរត់ គេប្រាប់ខ្ញុំថាពួកតាខាង។ តាខាង និងបងហែម ជាមនុស្សតែមួយ”។

ប្រតិចារឹកជាភាសាខ្មែរ៖

“ប្រហែលជាម៉ោង ៩ ឬ ១០ ព្រឹក **ថ្ងៃទី 0៦ ខែ មករា ឆ្នាំ ១៩៧៩** មានកិច្ចប្រជុំមួយនៅពុទ្ធិកវិទ្យាល័យសុរាម្រិត។ ដោយសារឃើញកិច្ចប្រជុំនេះនិយាយពីឃ្លាំងរដ្ឋ **ទើបខ្ញុំគិតថាបងហែម គ្រប់គ្រងឃ្លាំងរដ្ឋទៀត។ នេះគឺដើម្បីបញ្ជាក់ថា បងហែម មានអង្គភាពគ្រប់គ្រងមិនមែនជាមន្ទីរដែលធ្វើការតែហ្នឹងក្រដាសទេ។** ក្រោយមកទៀត ពេលយួនចូលមកដល់ពួកយើងរត់ គេប្រាប់ខ្ញុំថាពួកតាខាង។ ខ្ញុំប្រាប់គេថា ខាងណោះក៏តាខាងដែរ។ សរុបមករឿងទាំងអស់នេះជារឿងដែលខ្ញុំបានដឹង បានជួប បានឮ”។

១៦. នៅទំព័រ ៩៦ នៃប្រតិចារឹកដដែល៖

ប្រតិចារឹកជាភាសាបារាំង៖

"សំណួរ៖ តើលោកដឹងថាឃ្លាំងរដ្ឋមានទំនាក់ទំនងយ៉ាងម៉េចទៅនឹងបងហែម?

ចម្លើយ៖ ខ្ញុំស្គាល់អ្នកទទួលខុសត្រូវឃ្លាំងរដ្ឋ ក៏ប៉ុន្តែ នៅថ្ងៃទី 0៦ ខែ មករា ឆ្នាំ ១៩៧៩ ពេលខ្ញុំឃើញអ្នកទទួលខុសត្រូវឃ្លាំងរដ្ឋចូលរួមប្រជុំ ក្រោមបទឧទ្ទេសនាមរបស់បងហែម ខ្ញុំគិតថាបងហែមជាអ្នកគ្រប់គ្រងឃ្លាំងរដ្ឋ"។

ប្រតិចារឹកជាភាសាខ្មែរ៖

"សំណួរ៖ តើលោកដឹងថាឃ្លាំងរដ្ឋមានទំនាក់ទំនងយ៉ាងម៉េចទៅនឹងបងហែម?

ចម្លើយ៖ ខ្ញុំស្គាល់អ្នកទទួលខុសត្រូវឃ្លាំងរដ្ឋ ក៏ប៉ុន្តែ នៅថ្ងៃទី 0៦ ខែ មករា ឆ្នាំ ១៩៧៩ ពេលខ្ញុំឃើញអ្នកទទួលខុសត្រូវឃ្លាំងរដ្ឋចូលរួមប្រជុំ ក្រោមបទឧទ្ទេសនាមរបស់បងហែម ខ្ញុំគិតថាបងហែម**ប្រហែលជា**អ្នកគ្រប់គ្រងឃ្លាំងរដ្ឋ"។

១៧. ច្បាស់ណាស់ថា ខ្លឹមសារនៃចម្លើយមានលក្ខណៈខុសពីការពិត។ មេធាវីការពារក្ដីសូមភ្ជាប់ជាមួយ សំណើនេះនូវឧបសម្ព័ន្ធ ដែលបង្ហាញឧទាហរណ៍ត្រួសៗផ្សេងទៀតនៃកំហុស និងការបាត់ខ្លឹមសារ ដែលមិនត្រូវបានលើកឡើងនៅក្នុងសវនាការ។

១៨. មេធាវីការពារក្ដីបានរកឃើញភាពមិនត្រឹមត្រូវផ្សេងទៀត នៅក្នុងសក្ខីកម្មរបស់សាក្សីផ្សេងទៀត។

១៩. ឧទាហរណ៍ នៅក្នុងសវនាការ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២0១២[10] ចម្លើយពីរបន្តបន្ទាប់គ្នារបស់ លោកស្រី ប្រាក់ យុត (សាក្សី TCW-542) ត្រូវបានបកប្រែខុស នៅក្នុងប្រតិចារឹក៖

ប្រតិចារឹកជាភាសាបារាំង៖

"ចម្លើយ៖ ចំពោះខ្ញុំ ខ្ញុំជួយលេខាភូមិភាគ ដូចជា ជួយលេខាភូមិភាគកំពត ជាដើម។ តា ផន នៅទូកមាស។ ពួកគាត់នៅកន្លែងផ្សេងគ្នា។

សំណួរ៖ ដូច្នេះ មានន័យថា មនុស្សផ្សេងគ្នាមានទំនួលខុសត្រូវផ្សេងគ្នា នៅកន្លែងផ្សេងគ្នា

[10] សវនាការ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២0១២ ឯកសារ E1/33.1 ទំព័រ ៨0។

អ៊ីចឹងមែនទេ?

អ្នកបកប្រែអង់គ្លេស-បារាំង៖ អ្នកបកប្រែស្តាប់អត់ឮចម្លើយ។

ចម្លើយ៖ (ដើមដំបូងមិនត្រូវបានបកប្រែ) កង ចាប ត្រូវប្រជុំនៅទូកមាស និងនៅកន្លែងផ្សេងទៀត គឺកន្លែងណាដែលស្រួលប្រជុំ"។

ប្រតិចារឹកជាភាសាខ្មែរ ផ្សេងពីនេះ៖

"ចាស ម្នាក់ៗមានតួនាទីរៀងៗខ្លួន។ ដូចខ្ញុំហ្នឹង ខ្ញុំជួយអមគណៈស្រុកកំពត។ ដោយសារលេខាស្រុកកំពតមិនសូវចេះអក្សរ ខ្ញុំក៏ជួយអមដំណើរគាត់ ឬជួយតម្រង់គាត់ ខ្ញុំមិនធ្វើជាប្រធានគាត់ទេ។ គាត់ជាប្រធាន ខ្ញុំជួយគាត់។ តាផេន នៅស្រុកទូកមាស។ តាសៀន នៅស្រុកកំពង់ត្រាច ហើយតាទី នៅស្រុកឈូក។ យើងមានតួនាទីរៀងៗខ្លួន។ ឥឡូវនេះ គាត់ស្លាប់អស់ហើយ។ អត់មានសល់ទេ។

សំណួរ៖ ដូច្នេះ មានន័យថា មនុស្សផ្សេងគ្នាមានទំនួលខុសត្រូវផ្សេងគ្នា នៅកន្លែងផ្សេងគ្នា អ៊ីចឹងមែនទេ?

ចម្លើយ៖ ចាស!

សំណួរ៖ តើលោកស្រីនៅចាំទេថា មន្ទីរតំបន់ ៣៥ នៅកន្លែងណា?

ចម្លើយ៖ អាហ្នឹងអត់កំណត់"។

២០. ជាចុងក្រោយ ឧទាហរណ៍កាលពីពេលថ្មីៗនេះនៅក្នុងសវនាការថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២[11] នៅពេលលោក សាឡុត បាន (សាក្សី TCW-586) ផ្តល់សក្ខីកម្ម ចម្លើយខ្វែងគ្នាដែលត្រូវបានបកប្រែខុស មិនត្រូវបានកែតម្រូវទេ នៅក្នុងប្រតិចារឹកសវនាការស្តាពរ។ អ្នកបកប្រែបកថា សាក្សីទៅបឹងត្របែកដើម្បីជម្លៀស*ទាហាន* តាមពិតសាក្សីនិយាយថា ទៅដើម្បីប្រមូល*កម្លាំង*។

## ផលវិបាកចំពោះសុចរិតភាពនៃនីតិវិធី

២១. នៅក្នុងឧទាហរណ៍ដែលបានលើកឡើងខាងលើ មិនមានការចង្អុលបង្ហាញណាមួយក្នុងប្រតិចារឹកអំពីអត្ថិភាពនៃបញ្ហាបកប្រែ នៅក្នុងអំឡុងពេលសវនាការនោះទេ។

[11] សវនាការ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E1/68.1 ទំព័រ ៨០។

២២. មេធាវីការពារក្តីសូមរំឭកនូវមាត្រា ២៦ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣ និងមាត្រា ៤៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ២០០៤៖ ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង។

២៣. វិធាន ១១ នៃវិធានផ្ទៃក្នុង ស្តីពីអង្គភាពគាំពារការពារក្តី ចែងថា មេធាវីអន្តរជាតិត្រូវ *"ចេះភាសាខ្មែរ អង់គ្លេស ឬបារាំង ស្ទាត់ជំនាញ"*[12]។ ក៏ប៉ុន្តែ មេធាវីអន្តរជាតិទាំងបីរូបរបស់លោក ខៀវ សំផន និយាយភាសាបារាំង ហើយគ្មានកាតព្វកិច្ចធ្វើការ ដោយប្រើភាសាមួយផ្សេងទៀតឡើយ។

២៤. មេធាវីការពារក្តីលោក ខៀវ សំផន ជាក្រុមចម្រុះមានទាំងអ្នកនិយាយភាសាខ្មែរ និងបារាំង ប៉ុន្តែសមាជិកក្រុមជនជាតិខ្មែរគ្មានមុខងារ និងគ្មានពេលវេលា ក្នុងការពិនិត្យផ្ទៀងផ្ទាត់ភាពអាចទុកចិត្តបាននៃប្រតិចារឹកទាំងអស់ នៅខណៈដែលសវនាការលើអង្គសេចក្តីកំពុងប្រព្រឹត្តទៅនោះទេ។

២៥. មេធាវីការពារក្តីព្រួយបារម្ភអំពីអត្ថិភាពនៃកំហុសផ្សេងទៀត ដែលអាចប៉ះពាល់ដល់សុចរិតភាពនៃនីតិវិធី ពីព្រោះខ្លួនមិនអាចស្រង់កំហុសជាលក្ខណៈប្រព័ន្ធនោះទេ។

២៦. អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមដកស្រង់មាត្រា ១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា៖

*"២. អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចមានចែងក្នុងមាត្រា ១៤ និង១៦ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ"*។

២៧. វិធាន ២១ នៃវិធានផ្ទៃក្នុង ចែងថា៖

*"១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្តន៍ និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់*

[12] វិធាន ១១ កថាខណ្ឌ ៤(គ)(៥) នៃវិធានផ្ទៃក្នុង។

*ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវភាពថ្លាភាព ផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធី ប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"*។

២៨. ការគោរពសុចរិតភាពនៃនីតិវិធីតម្រូវឲ្យមេធាវីទាំងអស់ទទួលបានឯកសារដូចគ្នា សម្រាប់ត្រៀមខ្លួនការពារកូនក្តី។ ក៏ប៉ុន្តែ មេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ផ្អែកលើប្រតិចារឹកជាភាសាបារាំងជាមូលដ្ឋាន សម្រាប់ត្រៀមលក្ខណៈសួរដេញដោលសាក្សី។ សំណៅជាភាសាបារាំងក៏នឹងត្រូវប្រើប្រាស់ផងដែរ សម្រាប់គាំទ្រដល់ការរៀបចំសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ ដូច្នេះ ក្រុមមេធាវីនិយាយភាសាបារាំងចាំបាច់ត្រូវមានប្រតិចារឹកជាភាសាបារាំងអាចទុកចិត្តបាន ដើម្បីកុំឲ្យចាញ់ប្រៀបគេ។

**<u>ការប៉ះពាល់ដល់សិទ្ធិរបស់មេធាវីការពារក្តី</u>**

២៩. ម្យ៉ាងវិញទៀត ភាពអាចភាន់ច្រឡំបាននៃប្រតិចារឹកស្តាពរជាភាសាបារាំង បង្កការព្រួយបារម្ភដល់មេធាវីការពារក្តី ចំពោះសិទ្ធិជាមូលដ្ឋានរបស់កូនក្តី និងសិទ្ធិរបស់មេធាវីការពារក្តី។

៣០. មេធាវីការពារក្តីសូមដកស្រង់មាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា៖

***"មាត្រា ១៣៖ សិទ្ធិរបស់ជនជាប់ចោទ***

*១. សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេស រួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃរ៍រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួនសិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យ ឬបាន*

*ពិនិត្យសាក្សីដាក់បន្ទុក"*។

៣១. មាត្រា ៣៥ ថ្មី នៃច្បាប់ឆ្នាំ២00៤ ស្ដីពីការបង្កើត អ.វ.ត.ក៖

***"មាត្រា ៣៥ ថ្មី៖***

*[...]*

*នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា សមស្របតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖*

*[...]*

*ង/ ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភ័ស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុកដែរ"*។

៣២. ការធានានេះក៏ត្រូវបានរំឭកផងដែរនៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[13]។

៣៣. ប្រតិចារឹកសវនាការផ្ទុកនូវសក្ខីកម្មរបស់សាក្សី ដែលជាភ័ស្តុតាង សម្រាប់ជាមូលដ្ឋានឲ្យចៅក្រមពិភាក្សាសម្រេច។ វិធាន ៨៧ នៃវិធានផ្ទៃក្នុង ចែងថា រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក[14] ហើយ *"សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភ័ស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយភ័ស្តុតាងនោះត្រូវឆ្លងកាត់ការជជែកដេញដោល"*[15]។

៣៤. ក៏ប៉ុន្តែ កំហុស និងការបាត់ខ្លឹមសារ ដែលមិនត្រូវបានកែតម្រូវ នៅក្នុងសក្ខីកម្មរបស់សាក្សី គឺមានភ័ស្តុតាងដោះបន្ទុកជាសក្ដានុពល។ មេធាវីអន្តរជាតិត្រូវអាចសួរសាក្សី ដោយប្រើប្រាស់ឯកសារសក្ខីកម្មត្រឹមត្រូវ។

---

[13] មាត្រា ១៤ កថាខណ្ឌ ៣(ង) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦។

[14] វិធាន ៨៧ កថាខណ្ឌ ១ នៃវិធានផ្ទៃក្នុង។

[15] វិធាន ៨៧ កថាខណ្ឌ ២ នៃវិធានផ្ទៃក្នុង។

៣៥. អង្គជំនុំជម្រះសាលាដំបូងត្រូវដឹងថា កំហុសដ៏សាមញ្ញមួយនៅក្នុងការប្រើប្រាស់ពាក្យពេចន៍អាចបណ្តាលឲ្យមានការវាយតម្លៃខុសទៅលើខ្លឹមសារសំខាន់នៃសក្ខីកម្ម ដោយសារតែភាពស្មុគស្មាញនៃសំណុំរឿង ០០២។

៣៦. មេធាវីការពារក្តីលោក ខៀវ សំផន សូមបញ្ជាក់ថា អវត្តមានប្រតិចារឹកត្រឹមត្រូវទៅនឹងសក្ខីកម្មរបស់សាក្សីប៉ះពាល់ដល់សិទ្ធិរបស់មេធាវីការពារក្តី។

## <u>សំណើ</u>

៣៧. វិធាន ៩៧ នៃវិធានផ្ទៃក្នុង ចែងថា៖

*៣. កំណត់ហេតុជាលាយលក្ខណ៍អក្សរប្រចាំថ្ងៃនៃដំណើរការនីតិវិធី ដែលធ្វើឡើងដោយក្រឡាបញ្ជី ត្រូវចាត់ទុកថាមានភាពត្រឹមត្រូវ ផ្ទុះបញ្ជាំងអំពីការប្រព្រឹត្តទៅពិតប្រាកដនៃសវនាការ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រតិចារឹក និងខ្សែអាត់សម្លេង ក្នុងករណីចាំបាច់ ត្រូវបានអនុញ្ញាតអោយយកមកប្រើប្រាស់ ដើម្បីបំពេញបន្ថែម ឬកែតម្រូវនូវកំណត់ហេតុជាលាយលក្ខណ៍ប្រចាំថ្ងៃនោះ នៅពេលណាក៏បាន។*

*៤. ពាក្យសុំអោយកែតម្រូវលើប្រតិចារឹក ត្រូវធ្វើជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើពាក្យសុំនោះ ក្នុងពេលណាមួយ ក្រោយរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដាក់ពាក្យសុំ"។*

៣៨. ដោយសារតែកំហុស និងការបាត់ខ្លឹមសារ ដែលបានស្រង់តាំងពីពេលចាប់ផ្តើមសវនាការ មានទំហំធំ និងច្រើន មេធាវីការពារក្តីលោក ខៀវ សំផន មិនអាចធ្វើសំណើសុំកែតម្រូវប្រតិចារឹកជាក់លាក់ណាមួយបានឡើយ។

៣៩. អាស្រ័យហេតុនេះ មេធាវីការពារក្តីលោក ខៀវ សំផន សូមបញ្ជាក់ថា ខ្លួនមិនអាចធ្វើការពិនិត្យឡើងវិញនូវប្រតិចារឹកជាភាសាបារាំងទាំងអស់ ដោយផ្ទៀងផ្ទាត់ជាមួយប្រតិចារឹកជាភាសាខ្មែរ តាំងពីពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី បានឡើយ។ វាជាការចាំបាច់ដែលមេធាវីការពារក្តីអាចមានប្រតិចារឹកសវនាការត្រឹមត្រូវ នៅពេលសាក្សីធ្វើសក្ខីកម្ម។

៤០. មេធាវីការពារក្ដីលោក ខៀវ សំផន សូមគូសបញ្ជាក់ផងដែរអំពីភាពចាំបាច់ដាច់ខាតក្នុងការចាត់វិធានការបច្ចេកទេសនាពេលសវនាការ ដើម្បីជៀសវាងបញ្ហាបណ្ដាលមកពីការមិនទុកពេល រវាងចម្លើយ និងសំណួរ ក៏ដូចជាបណ្ដាលមកពីការនិយាយលឿនពេក។ វិធានការទាំងនេះអាចជាការដំឡើងភ្លើងសញ្ញា ដែលបើកដោយអ្នកបកប្រែចុងក្រោយគេ ដើម្បីបញ្ជាក់អំពីការបញ្ចប់ការបកប្រែ និងបើកមីក្រូហ្វូនរបស់ភាគី។

៤១. មេធាវីការពារក្ដីលោកខៀវ សំផន សង្កេតឃើញថា វាជាការសំខាន់ក្នុងការលើកបញ្ហានេះឡើងក្នុងដំណាក់កាលនេះនៃកិច្ចពិភាក្សាដេញដោល ដោយសារតែសក្ខីកម្មរបស់សាក្សីមានចំនួនច្រើន និងញឹកញាប់ នៅចំពោះមុខអង្គជំនុំជម្រះ។ យើងខ្ញុំយល់ឃើញថា ស្ថានភាពនេះនៅអាចកែកុនបានក្នុងដំណាក់កាលនេះនៃនីតិវិធី មុនពេលវាបង្កជាផលវិបាកមិនអាចដោះស្រាយបាន។

## អាស្រ័យហេតុនេះ

៤២. មេធាវីការពារក្ដីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- បង្គាប់ឲ្យពិនិត្យមើលឡើងវិញនូវប្រតិចារឹកសវនាការជាភាសាបារាំងទាំងអស់ ដោយផ្ទៀងផ្ទាត់ជាមួយប្រតិចារឹកជាភាសាខ្មែរ តាំងពីពេលចាប់ផ្ដើមសវនាការលើអង្គសេចក្ដី។
- បង្គាប់ឲ្យចាត់វិធានការបច្ចេកទេសក្នុងពេលសវនាការ ដើម្បីជៀសវាងបញ្ហាបណ្ដាលមកពីការមិនទុកពេល រវាងចម្លើយ និងសំនួរ ក៏ដូចជាបណ្ដាលមកពីការនិយាយលឿនពេក។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |